# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ បប

ភ្នំពេញ, ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០០៦

## បទបញ្ជា
## ស្តីពី
## ការគ្រប់គ្រង និង ការត្រួតពិនិត្យ លើការប្រើប្រាស់ឈរយន្តកាត់-អារឈើ

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការលុបបំបាត់ទាំងស្រុងនូវអំពើអនាធិបតេយ្យកាប់បំផ្លាញព្រៃឈើ ជាពិសេស ដើម្បីទប់ស្កាត់ បង្ក្រាប និង លុបបំបាត់ ការកាប់រានព្រៃឈើ ការឈូសឆាយដីព្រៃឈើគ្រប់ប្រភេទ (ដីព្រៃឈើ ដីព្រៃលិចទឹក និងដីព្រៃក្នុងតំបន់ការពារធម្មជាតិ) ដើម្បីហ៊ុំព័ទ្ធយកដីធ្វើជាកម្មសិទ្ធិ ដែលជាប្រភពដ៏គ្រោះថ្នាក់បំផុតនាំឱ្យមានទំនាស់ដីធ្លី ក៏ដូចជាអំពើពុករលួយផងដែរនោះ **រាជរដ្ឋាភិបាល ចាំបាច់ដាក់ចេញនូវបទបញ្ជាបន្ថែមជាបន្ទាន់ឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តដូចខាងក្រោម ៖**

១- រាល់ការនាំចូល ការប្រើប្រាស់ ការធ្វើសន្និធិ ការរក្សាទុក ការលក់ដុំ ឬលក់រាយ ការដឹកជញ្ជូន ការទិញដូរ និងការធ្វើអំណោយនូវឈរយន្តកាត់-អារឈើ សម្រាប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ឬឯកជន ត្រូវមានការអនុញ្ញាត និងវាយតម្លៃ ភាពសមស្រប ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ)។ ក្នុងករណីប្រើប្រាស់ឈរយន្តកាត់-អារឈើ ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ត្រូវមានគោលការណ៍ឯកភាពពីក្រសួងបរិស្ថាន មុនពេលដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) សម្រេចផ្តល់ការអនុញ្ញាត ។

២- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយនឹងអាជ្ញាធរដែនដីខេត្ត ក្រុង បើកយុទ្ធនាការជាប្រចាំដើម្បីចុះចាប់ឃាត់ទុក និងប្រមូល ជាអាទិ៍ តាមលំនៅដ្ឋាន ដេប៉ូឈើ ឬគ្រឿងសង្ហារឹម កន្លែងលក់ដុំ ឬលក់រាយ រោងសន្និធិ មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬនៅទីកន្លែងផ្សេងទៀត នូវឈរយន្តកាត់-អារឈើ ដែលមិនបានទទួលការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) ។

៣- ចំពោះឈរយន្តកាត់-អារឈើ ដែលបានទទួលការអនុញ្ញាតរួចហើយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (រដ្ឋបាលព្រៃឈើ) និង ក្រសួងបរិស្ថាន ត្រូវចុះធ្វើការត្រួតពិនិត្យ ស្រង់ស្ថិតិ និង ចុះបញ្ជិកាឱ្យបានច្បាស់លាស់ ដើម្បីគ្រប់គ្រងតាមសមត្ថកិច្ចរៀងៗខ្លួន។

៤- ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ពន្ធ័ ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ដែលមានជាធរមានឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត ជាពិសេស អំពីទោសប្បញ្ញត្តិចំពោះជនទាំងឡាយណា ដែលប្រើប្រាស់ឈរយន្តកាត់-អារឈើ ដោយគ្មានការអនុញ្ញាត ឬឃុបឃិតឱ្យមានការប្រើប្រាស់ឈរយន្តកាត់-អារឈើ ដោយខុសច្បាប់ ដើម្បីប្រមូលផល អនុផលព្រៃឈើ កាប់រានព្រៃឈើគ្រប់ប្រភេទ (ដីព្រៃឈើ ដីព្រៃលិចទឹក និងដីព្រៃក្នុងតំបន់ការពារធម្មជាតិ ) ដើម្បីហ៊ុំព័ទ្ធយកដីធ្វើជាកម្មសិទ្ធិ។

៥- ក្រសួង ស្ថាប័នពាក់ព័ន្ធ គយ និងរដ្ឋាករ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវសហការអនុវត្តបទបញ្ជានេះក្នុងស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយរាយការណ៍ប្រចាំខែអំពីលទ្ធផលជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុតឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើរាតយកដីធ្វើកម្មសិទ្ធិ តាមករណីជាក់ស្តែងនីមួយៗ។ កងយោធពលខេមរៈភូមិន្ទ មានភារកិច្ចជួយសហការបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចខាងលើ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងស៊ីជំរៅ តាមប្រពន្ធ័ផ្សព្វផ្សាយព័ត៌មាន ក្នុងរយៈពេល ៣ ខែ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានប្រតិបត្តិ គជដព
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចចំណុចទី ៥
- ឯកសារ កាលប្បវត្តិ

ហ៊ុន សែន